មាត្រា ២ .-

សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ចាន់ សុគុ

## III- រាជរដ្ឋាភិបាល

## អនុក្រឹត្យ

## អនុក្រឹត្យលេខ ១៦ អនក្រ.បក

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
~~~

- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ .-**

ត្រូវបានបង្កើត វិទ្យាស្ថានយោធាកម្ពុជា ដែលមានស្ថាប័នចំណុះមួយចំនួនរួមមាន :

- មជ្ឈមណ្ឌលហ្វឹកហ្វឺនយុទ្ធសាស្ត្រយោធា
- មជ្ឈមណ្ឌលហ្វឹកហ្វឺនបញ្ជាការ និងសេនាធិការ
- មជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបរទេស និងចំណេះទូទៅ

**មាត្រា ២ .-**

វិទ្យាស្ថានយោធាកម្ពុជា ជាមជ្ឈមណ្ឌលហ្វឹកហ្វឺន ចំណុះឱ្យក្រសួងការពារជាតិ មានភារកិច្ចដឹកនាំ និងគ្រប់គ្រង ហ្វឹកហ្វឺន បណ្តុះបណ្តាល បំប៉ននាយទាហាននៃកងទ័ពទាំងបីប្រភេទ ចាប់ពីថ្នាក់មេបញ្ជាការកងវរសេនាតូច និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ ហ្វឹកហាត់អំពីការងារយុទ្ធវិធី-យុទ្ធសាស្ត្រយោធា ការងារបញ្ជាការ-សេនាធិការ ចំប៉ននាយទាហានជាន់ខ្ពស់ និងវិន័យ សណ្តាប់ធ្នាប់ បទបញ្ជាផ្ទៃក្នុង ជូរកងទ័ពភាសាបរទេស ព្រមទាំងចំណេះទូទៅសមស្របទៅតាមសភាពការណ៍រីកចំរើនរបស់មាតុភូមិ និងការរីកចំរើនរបស់កងយោធពលខេមរភូមិន្ទ ។ ក្រៅពីភារកិច្ចខាងលើ វិទ្យាស្ថានយោធាកម្ពុជា ត្រូវបានទទួលភារកិច្ចបន្ថែមទៀត តាមការប្រគល់ភារកិច្ចរបស់ក្រសួងការពារជាតិ ។

**មាត្រា ៣ .-**

រចនាសម្ព័ន្ធ និងក្របខ័ណ្ឌរបស់វិទ្យាស្ថានយោធាកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធចាត់តាំង និងក្របខ័ណ្ឌរបស់វិទ្យាស្ថានយោធាកម្ពុជា ចាប់ពីថ្នាក់ក្រោមមណ្ឌលចុះ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា ៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ នៃយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៧.-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

**<u>សម្គាល់</u> :**

ភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០១

យល់ព្រម និង ឯកភាព

លើរចនាសម្ព័ន្ធចាត់តាំង វិទ្យាស្ថានយោធាកម្ពុជា

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

## រចនាសម្ព័ន្ធចាត់តាំង
## វិទ្យាស្ថានយោធាកម្ពុជា




## អនុក្រឹត្យលេខ ១៧ អនក្រ.បក
## ស្តីពីការ
## បង្កើតសង្កាត់កោះរ៉ុង ចំណុះខណ្ឌមិត្តភាព ក្រុងព្រះសីហនុ

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
~~~